ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ: ០៣ ប្រ

ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០០៣

សាលដីកា

លេខ: ៥២

ចុះថ្ងៃទី ១១ខែមីនា ឆ្នាំ២០០៣

## តាងនាមប្រជារាស្ត្រខ្មែរ

### តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១១ ខែ មីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ:-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ស៊ិន អ៊ីម ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៤- លោក ព្រាក់ គឹមសាន ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រម

ក្រឡាបញ្ជី

លោក ខៅ សុវណ្ណ

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ២៣៦ "ឃ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨៣៨ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទលោក គីម សុខេ "ដើមបណ្តឹងសាទុក្ខ" អាយុ ៣៩ ឆ្នាំ ជាតិ ខ្មែរ លក់ដូរ ទីលំនៅផ្ទះលេខ ៣៤៤ ផ្លូវលេខ ៣៦៩ សង្កាត់ផ្សារអំពៅ ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ តំណាងដោយលោក ផា សំបូរណ៍ អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើការនៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទីលំនៅផ្ទះលេខ៥១ខេហ្វុត ផ្លូវ ៤០២ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

- និងចុងចម្លើយ លោក លឹម ញុងស្រេង "ចុងបណ្តឹងសាទុក្ខ" ទីលំនៅផ្ទះលេខ៩៤អ៊ី០ ផ្លូវ១៣៦ សង្កាត់ផ្សារកណ្តាល ២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ តំណាងដោយឈ្មោះ- ភោគ សួង អាយុ ៤៥ ឆ្នាំ ជាតិ ខ្មែរ មុខរបរ មេការ របស់ លឹម ញុងស្រេង ទីលំនៅភូមិចុងអូរ ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។

- តតិយជន:១- លោក ឃី ទេព្វង អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរ:លក់ទិញអេតចាយ ទីលំនៅផ្ទះលេខ៦ខប ផ្លូវ ១៨៧ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

២- លោក វ៉ាន់ នី អាយុ ៤៣ ឆ្នាំ ជាតិខ្មែរ មុខរបរ:លក់ដែក ទីលំនៅ ផ្ទះលេខ ២៨ ក្រុម១៧ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

មានមេធាវី លោក រ៉េត ឃាំ ការពារអោយតតិយជន
កម្មវត្ថុបណ្តឹង: ប្តឹងទាមឃាត់ឥវ៉ាន់ និង សំភារៈ "អេតចាយ" ចំនួន ០៣ឡាន
ក្នុងរោងចក្រកិនដែក លីម ហុងស្រេង បណ្តោះអាសន្ន

តាមបណ្តឹងសាទុក្ខលេខ ៤៨៣ ចុះថ្ងៃទី២៥.១២.២០០២ របស់ឈ្មោះ ជា សំបូរណ៍ តំណាងឈ្មោះ- គីម សុខេ ប្តឹងសាទុក្ខនឹងសាលដីកាលេខ ២៣៦ "ឃ" របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ០៣ ប្រ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៣ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងសុំ ចុះថ្ងៃទី ២៨.១០.២០០២ របស់លោក គីម សុខេ ប្តឹងសុំរឹបកម្មវត្ថុ ខាងលើ ដោយសំអាងហេតុថា: ឈ្មោះ លីម ហុងស្រេង បានទិញសំភារៈរបស់ខ្លួនទៅមិនទាន់អោយប្រាក់ ដែលមានចំនួន ៦.៨៤៧ ដុល្លាអាមេរិក ហើយសន្យាលងទៅថ្ងៃទី ២៧.១០.០២ តែគេបដិសេធព្រមសង តាមកាលកំណត់ ពេលខ្លួនទៅដល់រោងចក្រដើម្បីទារលុយ ខ្លួនឃើញមានការដឹកជញ្ជូនឥវ៉ាន់និងសំភារៈ "អេតចាយ" ចំនួន ០៣ឡាន ចេញពីរោងចក្រកិនដែកពីសំណាក់អ្នកផ្សេង ក្រោយពីឃើញខ្លួនប្តឹង សមត្ថកិច្ចមូលដ្ឋាន ដើម្បីធ្វើការឃាត់សំភារៈទាំងនោះ ដើម្បីធ្វើការដោះស្រាយ ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ២៧ "ក" ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៨.១០.២០០២ របស់ឈ្មោះ គីម សុខេ ទុកជាត្រឹមត្រូវ តាមទំរង់ និង គតិច្បាប់ ។

២- ឃាត់ឥវ៉ាន់ "អេតចាយ" និង សំភារៈចំនួន ០៣ឡាន ដែលដឹកចេញពីរោងចក្រ កិនដែក និងឃាត់មិនអោយយកចេញនូវឥវ៉ាន់ "អេតចាយ" និងសំភារៈផ្សេងទៀតពីក្នុងរោងចក្រ កិនដែកដែលជារបស់ឈ្មោះ ហុង ស្រេង ដែលរោងចក្រមានទីតាំងនៅភូមិត្រពាំងទំពេក សង្កាត់- ចោមចៅ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។

៣- អោយឈ្មោះ គីម សុខេ បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លៃ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល សរុប ២.០០០រៀល ដែលឈ្មោះ គីម សុខេ បានបង់ ទុកជាស្របតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៤- ដីកាសំរេចនេះមានអានុភាពអនុវត្តភ្លាមៗ ទោះបីមានបណ្តឹងទាស់ក៏ដោយ ។

៥- ករណីភាគីណាមិនសុខចិត្តនឹងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ "ដប់ប្រាំថ្ងៃ" ចាប់តាំងពីថ្ងៃបានទទួលដំណឹងពីដីកានេះ ។

ដីកាសំរេចតាមពាក្យសុំនេះត្រូវបានលោក ឃី ទេឡុង និង លោក វ៉ាន់ នី ប្តឹងទាស់ តាមបណ្តឹងលេខ ៥៥ "ក" ចុះថ្ងៃទី ០៧.១១.២០០២ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ០៩ប្រ "ក" ចុះថ្ងៃទី ២៨.១១.២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:-

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៩.១០.២០០២ របស់ឈ្មោះ ឃី ទេឡុង និង ឈ្មោះ- វ៉ាន់ នី ដើមបណ្តឹងទាស់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្លូវពីគតិច្បាប់ ។

២- តំកល់ដីកាសំរេចតាមពាក្យសុំលេខ ២៧ "ក" ចុះថ្ងៃទី ២៨.១០.២០០២ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

---៣-----

៣_ អោយកត់ត្រា និងប្រគល់វត្ថុតាងសំភារៈអេតចាយដែលបានឃាត់ទុកអោយទៅ ឈ្មោះ គឹម សុខេ យកគ្រប់គ្រងថែរក្សាជាបណ្តោះអាសន្ន រង់ចាំតុលាការសំរេចលើអង្គសេចក្តីចប់ជាស្ថាពរ ។

៤_ ទំរង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីការនៃពីបប្រាក់ ២០០រៀល រង្វាន់អ្នកប្រគល់ដីកាដីកា ២.០០០រៀល បូកសរុប _ ៤.០០០រៀល តាមបញ្ជាប័ណ្ណពីប្រាក់ប្រដាប់ក្តី ។

៥_ ដីការនេះមានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៦_ បើភាគីណាមិនសុខចិត្តនឹងដីការនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០២ខែ "ពីរខែ" គិតចាប់តាំងពីថ្ងៃនេះតទៅ ។

ដីកាសំរេចកិច្ចការប្រញាប់នេះត្រូវបានលោក ង៉ែត យ៉ាំ ជាមេធាវីតំណាងដើមប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ៦០ "គ" ចុះថ្ងៃទី ០៤.១២.២០០២ លើចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៣៦ "ឃ" ចុះថ្ងៃទី ២៤.១២.២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:_

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤.១២.០២ របស់លោកមេធាវី ង៉ែត យ៉ាំ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ បដិសេធដីកាសំរេចកិច្ចការប្រញាប់លេខ០៩ប្រ "ក" ចុះថ្ងៃទី ២៨.១១.២០០២ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣_ ប្រគល់វត្ថុតាង "ដែកអេតចាយ" និងសំភារៈផ្សេងទៀតដែលឈ្មោះលឹម ហុងស្រេង បានលក់អោយឈ្មោះ ឃី ទេឡុង និង ឈ្មោះ វ៉ាន់ នី អោយទៅឈ្មោះ ឃី ទេឡុង និងឈ្មោះវ៉ាន់ នី ដឹកចេញពីរោងចក្រកិនដែកដែលជារបស់ឈ្មោះ លឹម ហុងស្រេង ស្ថិតនៅភូមិត្រពាំងទំមេក សង្កាត់ _ ចោមចៅ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ យកទៅគ្រប់គ្រងវិញ ។

៤_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីការនៃពីបប្រាក់ ៤៥០ រៀល ចំណាយលើការប្រគល់ដីកាដីកា ៥.០០០រៀល និង អាជ្ញាធរតុលាការ ៥.០០០រៀល ។

៥_ សាលដីការនេះមានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៦_ សាលដីការនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៨៣ ចុះថ្ងៃទី ២៤.១២.២០០២ របស់ឈ្មោះ ជា សំបូរស៊ី តំណាងឈ្មោះគឹម សុខេ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៣៦ "ឃ" ចុះថ្ងៃទី ២៤.១២.២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ១០.០១.២០០៣ របស់ឈ្មោះ គឹម សុខេ ។

បានឃើញសារណាចុះថ្ងៃទី ១៧.០១.២០០៣ របស់ឈ្មោះឃី ទេឡុង និងឈ្មោះ វ៉ាន់ នី ។

បានឃើញសារណាចុះថ្ងៃទី ១៧.០១.២០០៣ របស់ឈ្មោះ អោក សួង ។

----៤----

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖ ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ តំណាងមហាអយ្យការ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោក ជា សំបូរណ៍ តំណាងអោយលោក គីម សុខេ ជាដើមចោទ និងជាម្ចាស់បណ្តឹងសារទុក្ខ ឆ្លើយនៅពេលសវនាការថា ៖ បានជាខ្លួនប្តឹងសារទុក្ខពីសាលដីការបស់សាលា-ឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់ក្តីមិនត្រឹមត្រូវ ។ ឈ្មោះ ឃី ទៀង និង វ៉ាន់ នី សំអាងតែលើវិក័យប័ត្រ ដែលមានតែឈ្មោះ មិនបានបញ្ជាក់ការដឹកឥវ៉ាន់ចេញទេ ។ ខ្ញុំមិនទាមទារឥវ៉ាន់នេះទេ គ្រាន់តែអោយតុលាការក្រុងភ្នំពេញ ហៅ លឹម ហុងស្រេង មកកាត់សំអង្គសេចក្តី ។ គេនមាយនេះខ្ញុំគ្រប់គ្រងជាបណ្តោះអាសន្ននៅបារ៉ាវសំពៅ ។ ពីវ៉ាន់ទាំងនេះមានតំលៃតិចតួចណាស់មិនស្មើគាត់ជំពាក់ខ្លួនទេ ។ ខ្លួនប្រមូលឥវ៉ាន់ លឹម ហុងស្រេង នៅក្នុងរោងចក្រយកមកប្រមូលទុក ហើយបញ្ជីថ្លៃរោងចក្រមានសល់រោងដែកមួយ ផ្ទះថ្មមួយ ។ មុននឹងខ្លួនឃាត់ តតីយជនបានអារយកគ្រឿងចក្រអស់ នេះ ។ វិក័យប័ត្រគាត់ចេញក្រោយថ្ងៃដែលខ្លួនឃាត់ឥវ៉ាន់ទេ ។ លឹម ហុងស្រេង បាត់ខ្លួនប្រហែលថ្ងៃទី ២៥.១០.០២ ។ ដែកនោះទុកយូរអាចបាត់បង់គុណភាព ខ្លួនសូមអោយតុលាការលក់ដែកយកលុយតំកល់នៅតុលាការ ។ សំណូមពរ ៖ សូមតុលាការបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង បញ្ជូនសំណុំរឿងទៅតុលាការក្រុងភ្នំពេញ ។

បានស្តាប់ចម្លើយរបស់លោក ឃី ទៀង ជាតតីយជន និង ជាចុងបណ្តឹងសារទុក្ខ ឆ្លើយនៅពេលសវនាការថា ៖ ឈ្មោះ គីម សុខេ បានឃាត់ឥវ៉ាន់ លឹម ហុងស្រេង ដែលគាត់បានប្រគល់អោយខ្លួនតាំងពីថ្ងៃទី ២១.១០.០២ ។ ថ្ងៃទី ២៥.១០.០២ គាត់មិនទាន់គេចខ្លួនទេ តែដោយ គីម សុខេ ទៅប៉ូលីសទៅច្រើនពេក គាត់ក៏គេចខ្លួន ។ ខ្លួនរកស៊ីជាមួយលឹម ហុងស្រេង ច្រើនខែ ច្រើនឆ្នាំមកហើយ ខ្លួនទិញដែកពីប្រទេសវៀតណាមអោយគាត់ គាត់លក់ដែកកំទេចបថីអោយខ្លួនវិញ ។ ខ្លួនទិញគាត់តែការលុយដែលគាត់ជំពាក់ខ្លួនតែម្តង ។ ថ្ងៃទី២៥.១០.០២ ពេលការប្រជុំជាមួយខ្លួន គឺគាត់នៅទេ ។ ខ្លួនយកឥវ៉ាន់នៅថ្ងៃទី២១ , ២៣ , ២៤ ចំនួន៣ឡាន ដែលរៀបដឹកចេញ ស្រាប់តែ គីម សុខេ បានហៅប៉ូលីសទៅឃាត់ឡាន និងនៅមានសល់ដែក ដែលត្រូវប្រគល់អោយខ្លួន ហើយខ្លួនមិនទាន់យកចេញពីរោងចក្រ ។ គាត់ប្រាប់មេការគាត់អោយប្រគល់ដែកអោយខ្លួន និង វ៉ាន់ នី ។ ខ្លួនមិនព្រមអោយលក់ឡាយឡុងយកលុយទេ ។

បានស្តាប់ចម្លើយរបស់លោក វ៉ាន់ នី ជាតតីយជន និង ជាចុងបណ្តឹងសារទុក្ខ ឆ្លើយនៅពេលសវនាការថា ៖ ខ្លួនបានទិញឥវ៉ាន់តម្លៃ ៣.២០០ដុល្លារអាមេរិក ហើយបានប្រគល់លុយអោយ លឹម ហុងស្រេង នៅថ្ងៃទី ២៥.១០.០២ ។ ខ្លួនអ្នកផ្គត់ផ្គង់គ្រឿងអគ្គិសនីអោយរោងចក្រ លឹម ហុងស្រេង ហើយគាត់មិនទាន់អោយលុយទេ ។ ខ្លួនសុំទុកដែកសិន មិនទាន់អោយលក់ឡាយឡុងទេ ។ សំណូមពរ ៖ សូមរក្សាសាលដីការបស់សាលាឧទ្ធរណ៍ ។

------

បានស្តាប់ចម្លើយរបស់លោក ភោគ សួង តំណាងអោយលោក លឹម ហុងស្រេង ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា ៖ខ្លួនជាអ្នកមើលការខុសត្រូវ លក់ចេញ ទិញចូលក្នុងរោងចក្រ លឹម ហុងស្រេង ។ វ៉ាន់ នី និង ឃី ទេឡុង ជាអ្នកទិញស្រក់ ជាមួយ លឹម ហុងស្រេង ខ្លួនគ្រាន់តែជាអ្នកថ្លឹង ដើយថ្ងៃទី ២៥.១០.០២ បានធ្វើបញ្ជីកាត់កង ។ វិក័យប័ត្រលក់ចេញ ទិញចូល យកពីលោក ឃី ទេឡុង ខ្លួនគ្រាន់តែកត់បញ្ជីលក់ចេញ ។ វិក័យប័ត្រខ្លួនចេញអោយនៅថ្ងៃទី ២១.១០.០២ ហើយមិនបានដឹកដែកចេញទេ ដោយឡានខូច ។ ថ្ងៃទី ២៥.១០.០២ ខ្លួនទូរស័ព្ទទៅ លឹម ហុងស្រេង ចូល លុះដល់ថ្ងៃទី ២៦.១០.០២ ម៉ោង៩ព្រឹក ជាង ក៏ទូរស័ព្ទដែលចូល ។ ថ្ងៃទី ២៥.១០.០២ គាត់ប្រាប់ខ្លួនអោយប្រគល់អីវ៉ាន់អោយលោក – ឃី ទេឡុង និង វ៉ាន់ នី ហើយ លឹម ហុងស្រេង បែកពីខ្លួនប្រហែលម៉ោងពីររសៀលថ្ងៃទី ២៥.១០.០២ ។ គាត់ប្រាប់ខ្លួនថា បើទូទាត់ខុសលុយអោយគេយកពីយកទៅ ។ លឹម ហុងស្រេង អោយដឹកដែកនៅ ថ្ងៃទី ២៥.១០.០២ តែដោយឡានខូច និង លើកដែកមិនទាន់ ព្រោះតែនៅថ្ងៃទី២៦.១០.០២ គឹម ឈុខ មកឃាត់ ។ ខ្លួនសុំបញ្ជាក់ថា ៖ ដែកនេះប្រគល់អោយ ឃី ទេឡុង និង វ៉ាន់ នី ព្រោះគាត់បញ្ជាទូទាត់ប្រាក់ជំពាក់បំណុលយូរហើយ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក មេធាវី ង៉ែត យ៉ា ការពារអោយតតីយជន និង ជា ចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា ៖តតីយជនពិតជាបានទិញដែកអេតចាយពី លឹម ហុងស្រេង ដោយមានវិក័យប័ត្រត្រឹមត្រូវតាមរយៈមេការ ភោគ សួង និង ទូទាត់ប្រាក់ អោយ លឹម ហុងស្រេង រួចហើយ ហើយដែកនេះជារបស់ លឹម ហុងស្រេង ពិតប្រាកដមែន មិនមែនទិញពី គឹម ឈុខ ទេ ។ លោក លឹម ហុងស្រេង គាត់មិនទទួលស្គាល់វិក័យប័ត្រ ដែលថាគាត់ជំពាក់ប្រាក់ គឹម ឈុខ ទេ ដោយគ្មានគល់បញ្ជី ។ សូមឯកឧត្តមប្រគល់ដែក អេតចាយអោយកូនក្តីខ្លួន ដើម្បីលក់យកប្រាក់ ព្រោះកាលណាទុកយូរបណ្តាលអោយដែកខូចគុណភាព ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី , តតីយជន និង សេចក្តីសន្និដ្ឋាន ការពាររបស់មេធាវីតតីយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

--------

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៤៨៣ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់លោក ជា សំបូរណ៍ ជាតំណាងលោក គឹម តុខេ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដែកទំនាស់អោយតតីយជន ដោយអាងហេតុថា តតីយជនបានទិញមុនពេលដែលតុលាការហាមឃាត់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះដែកនេះជាកម្មវត្ថុនៃទំនាស់ហើយដើមចោទក៏ជាម្ចាស់បំណុលម្នាក់លើចុងចម្លើយដែរ ។

- យល់ឃើញថា នៅពេលសវនាការនេះ ដើមចោទនិងតតីយជន សុទ្ធតែបានឆ្លើយថា ដែកទំនាស់នេះបើរក្សាទុកយូរនឹងនាំអោយមានការបាត់បង់ខូចខាតខ្លះប្រាកដមែន ប៉ុន្តែដើមចោទបានសុំអោយលក់ឡាយឡុងយកលុយតម្កល់ទុកនៅតុលាការ រីឯតតីយជន បានទាមទារយកដែកនេះតាមការលក់ទិញ ។ ដូច្នេះដើម្បីការពារនូវផលប្រយោជន៍របស់គូភាគី និង តតីយជន គប្បីសំរេចតម្កល់សាលដីការបស់សាលា-ឧទ្ធរណ៍ ហើយសម្រេចបន្ថែមអោយតតីយជនយកប្រាក់ថ្លៃដែកទៅតម្កល់ទុកនៅតុលាការក្រុងភ្នំពេញ រង់ចាំតុលាការសំរេចដល់អង្គសេចក្ដី ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៣៦ "យ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ដោយគ្រាន់សំរេចបន្ថែមអោយតតីយជនតម្កល់ប្រាក់ថ្លៃដែកនៅតុលាការក្រុងភ្នំពេញ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី និង តតីយជន .

១- ទទួលបណ្ដឹងសាទុក្ខលេខ ៤៨៣ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់លោក ជា សំបូរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ២៣៦ "យ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ដោយសំរេចបន្ថែមអោយតតីយជនយកប្រាក់ថ្លៃដែកទៅតំកល់ទុកនៅ-តុលាការក្រុងភ្នំពេញជាមុនសិន មុននឹងប្រគល់ដែកទំនាស់នេះអោយតតីយជន តាមចំនួនដូចខាងក្រោម:

- លោក ឃី ទៀង ត្រូវតំកល់ប្រាក់ ២០៤២ ដុល្លាអាមេរិក ។
- [illegible] ត្រូវតំកល់ប្រាក់ ៣២០០ ដុល្លាអាមេរិក ។

៣_ ទឹបអ្នសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រៀល ដែលដើមចោទបានបង់គឺ:

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវ.. កាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់។
- ចំណាយលើការប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប១៩.០០០ រៀល ។

៤_សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៣ ។